CAMBODIA
Kingdom of Wonder

ក្រសួងទេសចរណ៍
លេខ ០៥៥៥ ទសក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០១៦

# របាយការណ៍

## លទ្ធផលកិច្ចប្រជុំ

## បូកសរុបលទ្ធផលការងារអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ឆ្នាំ២០១៥ ឆមាសទី១ ឆ្នាំ២០១៦ និងទិសដៅបន្ត ឆមាសទី២ឆ្នាំ២០១៦ និងឆ្នាំ២០១៧

## នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ខេត្តឧត្តរមានជ័យ

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ គណៈកម្មការអន្តរក្រសួងគ្រប់គ្រង និងរៀបចំអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងឆ្នាំ២០១៥ ឆមាសទី១ ឆ្នាំ២០១៦ នៅខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មការអន្តរក្រសួង **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ និង **ឯកឧត្តម យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នជាសមាជិកគណៈកម្មការអន្តរក្រសួង មជ្ឈមណ្ឌលឯកសារកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ។

អង្គប្រជុំបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងារកន្លងមកលើការងារអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអន្លង់វែងដែលសម្រេចបាននូវលទ្ធផលមួយចំនួនដូចខាងក្រោម៖

- បានរៀបចំគម្រោងសាងសង់ និងបោះបង្គោលព្រំទាំង១៤ចំណុច
- បានបន្តប្រមូលភស្តុតាងដែលនៅសេសសល់ ដើម្បីចងក្រងឯកសារប្រវត្តិសាស្ត្រអន្លង់វែង
- បានជួសជុលបន្ទប់ប្រជុំនៅតំបន់ក៣ (ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក)
- បានសាងសង់បញ្ជរព័ត៌មាននៅតំបន់ក១ (កន្លែងដុតខ្មោចប៉ុលពត)
- បានដាក់ស្លាកប៉ាណូផែនទីក្នុងរមណីយដ្ឋាន និងការអភិវឌ្ឍរចនាសម្ព័ន្ធនានាជាដើម

អង្គប្រជុំបានឯកភាពលើសៀវភៅរបាយការណ៍លទ្ធផលកិច្ចប្រជុំបូកសរុបលទ្ធផលការងារអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ឆ្នាំ២០១៥ ឆមាសទី១ ឆ្នាំ២០១៦ និងទិសដៅបន្តឆមាសទី២ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ សម្រាប់ធ្វើការបោះពុម្ពផ្សាយ (ដូចមានជូនភ្ជាប់)។

ជាទិសដៅអនុវត្តបន្តសម្រាប់ឆមាសទី២ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ គណៈកម្មការអន្តរក្រសួងបានដាក់ចេញនូវផែនការមួយចំនួនដូចជា៖

- បើកការដ្ឋានសាងសង់របង និងបោះបង្គោលព្រំដី
- រៀបចំប្លង់មេលំអិតសម្រាប់តំបន់ក១ (កន្លែងដុតខ្មោចប៉ុលពត) តំបន់ក២ (កន្លែងកាត់ទោសប៉ុលពត) តំបន់ក៤ (ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក) និងតំបន់ខ៥ (ផ្ទះតាម៉ុកសារមន្ទីរតាម៉ុក)
- ដាក់ឲ្យដំណើរការបណ្ណាល័យ និងកន្លែងផ្តល់ព័ត៌មានអំពីតំបន់ប្រវត្តិសាស្ត្រ
- ស្នើឲ្យអាជ្ញាធរខេត្តឧត្តរមានជ័យធ្វើរបាយការណ៍មកគណៈកម្មការអន្តរក្រសួងស្តីពីករណីប្រជាពលរដ្ឋបានរំលោភដីបឹងអន្លង់វែងឲ្យបានច្បាស់លាស់ដើម្បីសុំគោលការណ៍ពីរាជរដ្ឋាភិបាល។
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងមគ្គុទ្ទេសក៍ទេសចរណ៍អន្លង់វែង
- រៀបចំខ្សែទស្សនកិច្ចបេតិកភណ្ឌប្រវត្តិសាស្ត្រ (Heritage Network) ភ្ជាប់តំបន់អន្លង់វែងជាមួយតំបន់ទេសចរណ៍បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រពិភពលោកសៀមរាបអង្គរ ប្រាសាទព្រះវិហារ និងប្រាសាទវត្តភូប្រទេសឡាវ។

បន្ទាប់ពីបញ្ចប់កិច្ចប្រជុំ គណៈកម្មការអន្តរក្រសួងក៏បានចុះពិនិត្យនៅការដ្ឋានសាងសង់បញ្ជរព័ត៌មាននៅតំបន់ក១ (កន្លែងដុតខ្មោចប៉ុលពត ) និងតំបន់ក៣ (ផ្ទះកណ្តាលលើខ្នងភ្នំដងរែក) ដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំរួចរាល់។

មុននឹងបញ្ចប់ **ឯកឧត្តមរដ្ឋមន្ត្រី** និងជាប្រធានគណៈកម្មការអន្តរក្រសួង បានថ្លែងអំណរគុណចំពោះសមាជិកគណៈកម្មការដែលបានឆ្លៀតពេលវេលាដ៏មមាញឹក ក្នុងការមកចូលរួមកិច្ចប្រជុំនាថ្ងៃនោះ និងផ្តល់យោបល់យ៉ាងផុលផុសប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។៚

**បានឃើញ និងឯកភាព**
**ប្រធានគណៈកម្មការអន្តរក្រសួង**

**ថោង ខុន**
**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**អ្នកធ្វើរបាយការណ៍**

**ឌុក ឌីនោរ**
**អនុប្រធានលេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង**

ចម្លងជូន
-សមាជិកគណៈកម្មការអន្តរក្រសួង
-ឯកសារ-កាលប្បវត្តិ